# សុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ - កាតព្វកិច្ច នៅក្រោមច្បាប់ WHS

ម៉ូដែលនៃច្បាប់សុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការតម្រូវឱ្យនិយោជក់ថែរក្សាសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់មនុស្សនៅកន្លែងធ្វើការ។ នេះរួមមាន៖

- ការផ្តល់ និងការរក្សាបរិស្ថានការងារដែលគ្មានហានិភ័យចំពោះសុខភាព និងសុវត្ថិភាព
- ការផ្តល់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់ និងអាចចូលប្រើប្រាស់បានសម្រាប់សុខុមាលភាពរបស់បុគ្គលិកដើម្បីអនុវត្តការងាររបស់ពួកគេ និង
- ការតាមដានសុខភាពរបស់បុគ្គលិក និងលក្ខខណ្ឌនានានៅកន្លែងធ្វើការដើម្បីទប់ស្កាត់ជំងឺ ឬការរងរបួស។

## កាតព្វកិច្ចចំពោះបុគ្គលិក

អ្នកមានកាតព្វកិច្ចដើម្បីធានាសុខភាព និងសុវត្ថិភាពបុគ្គលិករបស់អ្នក។ អ្នកត្រូវតែលុបបំបាត់ចោលហានិភ័យនៃការឆ្លង COVID-19 ឬប្រសិនបើរឿងនេះមិនអាចធ្វើបានទេ អ្នកត្រូវការ កាត់បន្ថយជាអប្បបរមានៃហានិភ័យឱ្យបានច្រើនដែលអាចធ្វើបាន។

ការពារបុគ្គលិកពីហានិភ័យនៃការឆ្លង COVID-19 តាមរយ: ឧទាហរណ៍៖

- អនុវត្តការចាត់ចែងឱ្យធ្វើការពីផ្ទះ
- តម្រូវឱ្យបុគ្គលិកអនុវត្តការរក្សាគម្លាតរាងកាយពីគ្នា និងអនាម័យល្អ
- តម្រូវឱ្យបុគ្គលិកស្នាក់នៅផ្ទះនៅពេលឈឺ ហើយ
- សម្អាតកន្លែងធ្វើការជាប្រចាំ និងឱ្យបានហ្មត់ចត់។

## កាតព្វកិច្ចចំពោះមនុស្សដទៃទៀតនៅក្នុងកន្លែងធ្វើការ

អ្នកត្រូវតែធានាការងារនៃអាជីវកម្មរបស់អ្នកមិនធ្វើឱ្យសុខភាព និងសុវត្ថិភាពមនុស្សដទៃទៀតដូចជាអតិថិជន ភ្ញៀវ និងអ្នកមកទស្សនាប្រឈមនឹងហានិភ័យ។

ការពារបុគ្គលិកពីហានិភ័យនៃការឆ្លង COVID-19 តាមរយ: ឧទាហរណ៍ តម្រូវឱ្យពួកគេ៖

- អនុវត្តការរក្សាគម្លាតរាងកាយពីគ្នា រួមមានតាមរយៈការដឹកជញ្ជូន និងការបង់ប្រាក់ដោយមិនមានទាក់ទងគ្នា

- អនុវត្តអនាម័យល្អ និង
- ស្នាក់នៅឆ្ងាយពីកន្លែងធ្វើការ ប្រសិនបើមិនចាំបាច់ទេ

## កាតព្វកិច្ចដើម្បីថែរក្សាកន្លែងធ្វើការ និងបរិក្ខារសម្ភារ

អ្នកត្រូវតែថែរក្សាកន្លែងធ្វើការរបស់អ្នកដើម្បីធានាបរិស្ថានការងារមិនធ្វើឱ្យបុគ្គលិក និងអ្នកដទៃទៀតប្រឈមនឹង ហានិភ័យនៃការឆ្លង COVID-19។

ថែរក្សាបរិស្ថានការងារឱ្យមានសុវត្ថិភាពតាមរយៈ ឧទាហរណ៍៖

- សម្អាតកន្លែងធ្វើការជាប្រចាំ និងឱ្យបានហ្មត់ចត់
- ផ្លាស់ប្តូរការរៀបចំកន្លែងធ្វើការដើម្បីអនុញ្ញាតឱ្យមានការរក្សាគម្លាតរាងកាយពីគ្នា និង
- កម្រិតកំណត់ចំនួនមនុស្សនៅក្នុងកន្លែងធ្វើការ

អ្នកក៏ត្រូវតែផ្តល់សម្ភារៈបរិក្ខារឱ្យបានគ្រប់គ្រាន់នៅក្នុងកន្លែងធ្វើការរបស់អ្នក រួមមាន៖

- សម្ភារៈបរិក្ខារសម្រាប់លាងដៃដែលមានសាប៊ូ ទឹក និងក្រដាសជូត
- វត្ថុលាងដៃអនាម័យ ហើយនៅពេលមិនមានសម្រាប់បុគ្គលិកត្រូវឱ្យបុគ្គលិកលាងដៃរបស់ពួកគេ ហើយ
- បន្ទប់បុគ្គលិកត្រូវបានលាងសម្អាត និងអនុញ្ញាតឱ្យមានការរក្សាគម្លាតរាងកាយពីគ្នា។

ផ្តល់ឱ្យបុគ្គលិកនូវការឈប់សម្រាកជាប្រចាំដើម្បីប្រើប្រាស់សម្ភារបរិក្ខារ ជាពិសេសលាងដៃរបស់ពួកគេ។

## កាតព្វកិច្ចដើម្បីផ្តល់ព័ត៌មាន ការបណ្តុះបណ្តាល ការណែនាំ និងការមើលខុសត្រូវ

អ្នកត្រូវតែផ្តល់ឱ្យបុគ្គលិករបស់អ្នកនូវព័ត៌មាន ឬការបណ្តុះបណ្តាលដែលចាំបាច់ដើម្បីការពារពួកគេពីហានិភ័យនៃការឆ្លង COVID-19 ពីកន្លែងធ្វើការរបស់ពួកគេ។

នេះអាចរួមមាន៖

- ការណែនាំស្តីអំពីការលាងដៃឱ្យបានត្រឹមត្រូវ
- ការបណ្តុះបណ្តាលស្តីអំពីរបៀបធ្វើឱ្យត្រូវ និងប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួនចាំបាច់ណាមួយ
- ការបណ្តុះបណ្តាលស្តីអំពីរបៀប និងនៅពេលណាត្រូវសម្អាត

- ការណែនាំអំពីការរៀបចំកន្លែងធ្វើការនៅផ្ទះឱ្យមានសុវត្ថិភាព និង
- ការណែនាំអំពីការស្នាក់នៅផ្ទះពីការងារ ប្រសិនបើឈឺ។

## កាតព្វកិច្ចដើម្បីពិគ្រោះយោបល់

អ្នកត្រូវតែពិគ្រោះយោបល់ជាមួយបុគ្គលិកអំពីបញ្ហាសុខភាព និងសុវត្ថិភាពទាក់ទងនឹង COVID-19 ហើយផ្តល់ឱ្យបុគ្គលិកនូវឱកាសដើម្បីសម្តែងទស្សនៈ និងការព្រួយបារម្ភនានា។ ពិចារណាលើទស្សនៈទាំងនោះ និងផ្តល់ឱវាទដល់បុគ្គលិកអំពីលទ្ធផលនៃការពិគ្រោះយោបល់។

ពិគ្រោះយោបល់ជាមួយបុគ្គលិកនៅពេលអ្នក៖

- ដឹកនាំការវាយតម្លៃហានិភ័យ
- ធ្វើសេចក្តីសម្រេចចិត្តស្តីអំពីវិធានការត្រួតពិនិត្យសម្រាប់ការគ្រប់គ្រងហានិភ័យដូចជាការដាក់ឱ្យមានការរៀបចំធ្វើការពីផ្ទះ ឬការរឹតបន្តឹងនៅកន្លែងធ្វើការដើម្បីធានាឱ្យមានការរក្សាគម្លាតរាងកាយពីគ្នា។
- ធ្វើសេចក្តីសម្រេចចិត្តអំពីសម្ភារបរិក្ខារនៅកន្លែងធ្វើការ និង
- ស្នើសុំលើការផ្លាស់ប្តូរដទៃទៀត ដែលអាចប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់បុគ្គលិក។

អ្នកត្រូវតែធ្វើតាមនីតិវិធីពិគ្រោះយោបល់ណាមួយដែលបានយល់ព្រមហើយ។ ប្រសិនបើមានអ្នកតំណាងផ្នែកសុខភាព និងសុវត្ថិភាព អ្នកត្រូវតែរួមបញ្ចូលពួកគេនៅក្នុងការពិគ្រោះយោបល់។

## ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពី COVID-19 និងសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ សូមចូលទៅ គេហទំព័ររបស់ Safe Work Australia។